ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**♣**

តុលាការកំពូល

*♣*

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៦៣

ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០០៣

សាលដីកា

លេខ : ២៤១

ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៣

## គោរពនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឃឹម | ប៉ុណ្ណ | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៣-លោក | ជីវ | កេង | ជាចៅក្រម |
| ៤-លោក | យស់ | សូខឿន | ជាចៅក្រមរបាយការណ៍ |
| ៥-លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៦-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៧-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៨-លោក | ប៉ែន | សារឿន | ជាចៅក្រម |
| ៩-លោក | ម៉ុង | មុនីចរិយា | ជាចៅក្រម |

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ១១២ "ច" ចុះថ្ងៃទី ៣០-៩-២០០២ នៃសំណុំរឿងរដ្ឋប្បវេណី លេខ ៣៤ ចុះថ្ងៃទី ២១-៦-២០០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ នាយ សុឃីម " ជាចុងបណ្តឹងសាទុក្ខ " ភេទស្រី អាយុ ៣១ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិក្បាលស្ពាន ឃុំ ប៉ោយប៉ែត ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ នាយ ឃន "រ" ម្តាយឈ្មោះ ឡៅ ហួយ " រ " ។

និងចុងចម្លើយឈ្មោះ សុខ អឿន " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទ ស្រី អាយុ ៥៤ឆ្នាំ ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ សំ " ស " ម្តាយឈ្មោះ សុខ ចម " ស " ។

កម្មវត្ថុបណ្តឹង : ប្តឹងសុំអោយរុះរើផ្ទះដែលតសំយ៉ាបជាប់នឹងជញ្ជាំងផ្ទះល្វែងរបស់ខ្លួនចេញ

តាមបណ្តឹងសាទុក្ខលើកទី២ លេខ ៤៣៨ ចុះថ្ងៃទី ២២-១១-២០០២ របស់ឈ្មោះ សុខ អឿន ប្តឹងមិនសុខចិត្តពី សាលដីកាលេខ ១១២ "ច" ចុះថ្ងៃទី ៣០-៩-២០០២ របស់សាលាឧទ្ធរណ៍លើចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ៦៣ ចុះថ្ងៃទី ១០-០២-២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ០១-៦-១៩៩៨ របស់ដើមចោទឈ្មោះ ឆាយ សុឃីម បានឆ្លើយបញ្ជាក់ថា ខ្លួនប្ដឹងសុំអោយចុងចម្លើយរុះរើផ្ទះដែលបានតសំយ៉ាបជាប់នឹងផ្ទះល្វែងរបស់ខ្លួនចេញ ដោយហេតុថាធ្វើអោយជ្រាបទឹកចូលផ្ទះ របស់ខ្លួន និងស្ទះលូទឹក ។

បានឃើញសាលក្រម លេខ ០៨ ចុះថ្ងៃទី ១៥-០១-១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ០១-៦-១៩៩៨ របស់ដើមចោទឈ្មោះ ឆាយ សុឃីម ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-អោយឈ្មោះ សុខ អឿន ជាចុងចម្លើយរុះរើផ្ទះរបស់ខ្លួនចេញអោយផុតពីសំយ៉ាបផ្ទះរបស់ដើមចោទ និងផុតពីដីចិញ្ចើមថ្នល់សាធារណៈបន្ទាប់ពីសាលក្រមនេះ មានអានុភាពអនុវត្ត ។

៣-អោយឈ្មោះ សុខ អឿន ជាចុងចម្លើយ សងប្រាក់ប្រដាប់ក្ដី ចំនួន ៧.០០០ រៀល ដែលដើមចោទបានបង់ទុករួចហើយនោះសងទៅដើមចោទវិញ ។

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូភាគី ទុកសិទ្ធិប្ដឹងឧទ្ធរណ៍រយៈពីរខែគិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ សុខ អឿន ចុះថ្ងៃទី ១១-០២-១៩៩៩ ប្ដឹងមិនសុខចិត្តលើសេចក្ដីសំរេច នៃសាលក្រមទាំងមូល ។

បានឃើញសាលដីកា របស់សាលាឧទ្ធរណ៍ លេខ ៧៥១ ចុះថ្ងៃទី ១៤-១០-១៩៩៩ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១-០២-១៩៩៩ របស់ សុខ អឿន ជាចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៨ ចុះថ្ងៃទី ១៥-០១-១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ទុកជាបានការ ។

៣-សំរេចកាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ គឺ ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ ដីកាកោះ ៥.០០០ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ដែលដើមបណ្ដឹងបានបង់រួចហើយ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី ។ បើកផ្លូវប្ដឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខ របស់ឈ្មោះ សុខ អឿន ចុះថ្ងៃទី ០៥-១១-១៩៩៩ ប្ដឹងមិនសុខចិត្តលើ សេចក្ដីសំរេចនៃសាលដីកាទាំងមូល ។

បានឃើញ សាលដីការបស់តុលាការកំពូល លេខ ១៥ ចុះថ្ងៃទី ១៨-០១-២០០១ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៩២ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់អ្នកស្រី សុខ អឿន ទុកជាត្រឹមត្រូវ តាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧៥១ ចុះថ្ងៃទី១៤ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៣៥ ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០០ របស់តុលាការកំពូល ទៅសាលា-ឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រី ឆាយ សុឃីម បានបង់ជូនរួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៥-សាលដីកានេះ ប្រកាសទាសវនាការ ជាសាធារណៈនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០១ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍ លេខ ១០១ "ច" ចុះថ្ងៃទី ១៥-៨-២០០២ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណី លេខ ៣៤ ចុះថ្ងៃទី ២១-៦-២០០១ របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីការដ្ឋប្បវេណី ១៥ ចុះថ្ងៃទី ១៨-០១-២០០១ របស់តុលាការកំពូល ។

២-បង្គាប់អោយឈ្មោះ សុខ អឿន និងក្រុមគ្រួសារ រុះរើផ្ទះ និងសំណង់ផ្សេងៗ របស់ខ្លួន ចេញអោយផុតពីសំយ៉ាបផ្ទះរបស់ដើមចោទ និងផុតពីដីចិញ្ចើមផ្លូវសាធារណៈជាបន្ទាន់ ចាប់ពីពេលដែលសាលដីកានេះ ចូលជាស្ថាពរ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល គឺ ពន្ធហ៊ឹង និងពន្ធចុះបញ្ជីក្តី ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និង អាជ្ញាធរតុលាការ ៥.០០០រៀល។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខ ដើមចោទកំបាំងមុខចុងចម្លើយ បើកផ្លូវតវ៉ា តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងទាស់របស់ឈ្មោះ សុខ អឿន ចុះថ្ងៃទី ២៨-៨-២០០២ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃសាលដីកាទាំងមូល ។

បានឃើញ សាលដីការបស់សាលាឧទ្ធរណ៍ លេខ ១១២ "ច" ចុះថ្ងៃទី ៣០-៩-២០០២ ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ២៨-០៨-២០០២ របស់ឈ្មោះ សុខ អឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីកំបាំងមុខ លេខ ១០១ "ច" ចុះថ្ងៃទី ១៥-៨-២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលើកទី ២ លេខ ៤៣៨ ចុះថ្ងៃទី ២២-១១-២០០២ របស់ឈ្មោះ សុខ អឿន ស្ថិតនៅក្នុងកំណត់ ច្បាប់ ។

បានឃើញ សារណា ចុះថ្ងៃទី ០៤-៣-២០០៣ របស់ឈ្មោះ សុខ អឿន ។

បានឃើញ សារណាតប ចុះថ្ងៃទី ៣១-៣-២០០៣ របស់ឈ្មោះ ឆាយ សុឃីម ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

-បណ្តឹងសាទុក្ខរបស់ចុងចម្លើយស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

-សាលដីការដ្ឋប្បវេណី លេខ ១១២ " ច " ចុះថ្ងៃទី ៣០-៩-២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គង ទាំងទំរង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សុខ អឿន "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា :

ខ្លួនទិញដីនេះតាំងពីឆ្នាំ ៩៥ ពីឈ្មោះសម ប្រាថ្នា មានកិច្ចសន្យាទិញ-លក់ ត្រឹមត្រូវ ហើយការសង់ផ្ទះនេះ គឺម្ចាស់ដីជួយសង់អោយ គឺជញ្ជាំងផ្សេងពីគ្នាចន្លោះពីជញ្ជាំងផ្ទះដើមចោទ មកជញ្ជាំងផ្ទះខ្លួន ឃ្លាតគ្នាចន្លោះមួយតឹកផ្ទះខ្លួនមានលូ ។ កាលពីមុនផ្ទះខ្លួនមានទំហំ ៤ ម៉ែត្រ តែដោយគេពង្រីកផ្លូវ ខ្លួនបានកាត់អោយរដ្ឋអស់ ២ម៉ែត្រ នៅសល់ ២ម៉ែត្រ ទៀតដែលខ្លួនរស់នៅសព្វថ្ងៃ លក់ដូរបន្តិចបន្តួចដើម្បីដោះស្រាយជីវភាព ។

សុំអោយខ្លួនបានរស់នៅបន្តទៀតផងចុះ ព្រោះខ្លួនចាស់ហើយ មិនដឹងទៅរស់នៅទីណាទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឆាយ សុឃីម "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា :

ខ្លួនប្តឹងនេះ មិនមែនចង់បានដីនេះទេ គឺសុំអោយគាត់ធ្វើយ៉ាងណា កុំយកជញ្ជាំងផ្ទះខ្លួនធ្វើជាជញ្ជាំងផ្ទះរបស់គាត់ ព្រោះវានាំអោយជ្រាបទឹក ដោយសារគាត់យកជញ្ជាំងធ្វើអាងទឹក ម្យ៉ាងទៀតការសង់ផ្ទះរបស់គាត់ គឺធ្វើអោយស្ទះប្រព័ន្ធលូទឹក មិនមែនស្ទះតែផ្ទះរបស់ខ្លួនមួយទេ គឺស្ទះដល់អ្នកនៅខាងបន្តពីខ្លួនទៀត ។ ផ្ទះរបស់គាត់នេះ គឺស្ថិតនៅលើចិញ្ចើមផ្លូវទាំងស្រុង ហើយខាងរដ្ឋអំណាចបានជូនដំណឹងអោយគាត់រុះរើ តែគាត់រុះជញ្ជាំងឯជំបូលនៅដដែល គាត់ថាអោយរដ្ឋ ២ម៉ែត្រ គឺមិនពិតទេ ។ ចុងចម្លើយគាត់មានផ្ទះនៅ មានប្លង់ត្រឹមត្រូវ តែគាត់ជួលអោយគេ ។

មេធាវីរបស់ចុងចម្លើយ ធ្វើសេចក្តីសន្និដ្ឋានថា :

កូនក្តីខ្លួន និងដើមចោទទិញផ្ទះពីឈ្មោះ សម ប្រាថ្នា ដូចគ្នា តែកូនក្តីខ្លួនទិញដីមុនក្នុងឆ្នាំ ១៩៩៥ ឯដើមចោទទិញផ្ទះក្រោយកូនក្តីខ្លួននៅឆ្នាំ ១៩៩៨ ។ ហើយការប្តឹងរបស់ដើមចោទ មិនត្រឹមត្រូវទេ ព្រោះគាត់មិនមែនជារដ្ឋអំណាចទុកអោយរដ្ឋអំណាចដោះស្រាយ ហើយរដ្ឋអំណាចក៏មិនបានអោយដំណឹងពីការរុះរើលំនៅដ្ឋានរបស់កូនក្តីខ្លួនដែរ ដោយកូនក្តីខ្លួនបានអោយរដ្ឋអស់ ២ម៉ែត្រ ហើយ នៅសល់ ២ម៉ែត្រ នេះ មិនប៉ះពាល់ដល់ផ្លូវទេ ។

សុំអោយកូនក្តីខ្លួន រស់នៅលើដីនេះផង ដោយរង់ចាំការរុះរើរបស់រដ្ឋចុះ ព្រោះកូនក្តីខ្លួនគ្មានផ្ទះនៅទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២ លេខ៤៣៨ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០០២ របស់អ្នកស្រី សុខ អឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងតាមមាត្រា ២២៦ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

-យល់ឃើញថា តាមសារណាចុះថ្ងៃទី ០៤-៣-២០០៣ របស់អ្នកស្រី សុខ អឿន ថា ប្រសិនបើរដ្ឋតម្រូវអោយនាងខ្ញុំរុះរើផ្ទះចេញ ដើម្បីយកដីនោះទៅបំរើផលប្រយោជន៍សាធារណៈពិតមែន នាងខ្ញុំរីករាយនឹងប្រគល់ជូនភ្លាមគ្មានការតវ៉ា អ្វីបន្តិចសោះឡើយ ។ ដូច្នេះការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវហើយ ពីព្រោះថា អាជ្ញាធរឃុំ អាជ្ញាធរស្រុកនិងអាជ្ញាធរខេត្ត បានជូនដំណឹងរួចហើយ អោយអ្នកសាងសង់សំណង់លើដីចំណីផ្លូវសាធារណៈអោយរុះរើ សំណង់ទាំងអស់របស់ខ្លួនចេញ ។

-យល់ឃើញថា ការដែលចុងចម្លើយ និងមេធាវីរបស់ចុងចម្លើយលើកឡើងនៅពេលសវនាការនេះថា អ្នកស្រី ឆាយ សុឃីម មានបំណងយកដីទំនាស់នេះ ជាប្រយោជន៍ផ្ទាល់ខ្លួន ហើយថា ចុងចម្លើយបានរុះរើ ផ្ទះអស់ ២ម៉ែត្រ ជូនរដ្ឋធ្វើផ្លូវរួចហើយ នៅសល់ ២ម៉ែត្រ ទៀត ពុំមានប៉ះពាល់ដល់ដីចំណីផ្លូវទេនោះ ពុំមានភស្តុតាងគួរអោយជឿបានទេ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណី លេខ ១១២ " ច " ចុះថ្ងៃទី ៣០-៩-២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តីចំពោះមុខតុក្តី

១-ទទួលបណ្តឹងសាទុក្ខ លេខ ៤៣៨ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០២ របស់អ្នកស្រី សុខ អឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណី លេខ ១១២ " ច " ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០រៀល ដែលអ្នកស្រី សុខ អឿន បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៤-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៣ ។